# តម្លៃនៃការអប់រំបរិយាបន្ន

The Value OF Inclusive Education

**ប៉ាន់ សំណាង** មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១.សេចក្តីផ្តើម

*ការអប់រំ ចាប់បដិសន្ធិតាំងពីកូនៗនៅក្នុងផ្ទៃម្តាយដោយម្តាយឪពុកតែងនិទានរឿងអានអក្សរនេះនោះដែលបង្កប់នូវន័យល្អៗពោរពេញដោយខ្លឹមសារអប់រំដល់កូនៗរបស់ខ្លួនៗ ម្តាយនិងកូនមានសមានចិត្តចងគ្នា ពីព្រោះម្តាយជាអ្នកពរពោះៗពេលចម្រើនវ័យ ការអប់រំក៏ត្រូវឆ្លើយតបតាមអាយុកាលដែរៗ កុមារតូចដែលកើតមកដល់អាយុក្រោម៦ឆ្នាំ តែងមានការអភិវឌ្ឍលើផ្នែករាងកាយនិងស្មារតីដែលជាតម្រូវការចាំបាច់សម្រាប់កុមារៗ ការលូតលាស់ទាំងនេះ តែងមានឥទ្ធិពលគ្នាទៅវិញទៅមកៗ កុមារគ្រប់រូបមានសិទ្ធិទទួលបានការគាំទ្រពីឪពុកម្តាយនិងសហគមន៍របស់ពួកគេ ដើម្បីទទួលបានការរីកលូតលាស់រូបរាងកាយ ទទួលបានការសិក្សា និងមានការអភិវឌ្ឍបញ្ញាស្មារតីមុនដល់អាយុចូលសាលា ហើយពេលពួកគេដល់អាយុចូលរៀន ពួកគេត្រូវទទួលបានការសិក្សាតាមរយៈគ្រូបង្រៀន និងមិត្តរួមថ្នាក់ៗ នេះ មានន័យថា វាជាការអប់រំរួមបញ្ចូលដោយសិស្សឬកុមារមានស្ថានភាពជីវិត និងលក្ខណៈខុសៗគ្នាទាំងជីវភាពរស់នៅ ទាំងការទំនុកបម្រុងផ្សេងៗ រៀនថ្នាក់ជាមួយគ្នាៗ*

*ក្នុងបរិបទនៃការធ្វើសមាហរណកម្មក្នុងតំបន់និងពិភពលោក សេវាអប់រំកុមារតូចបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យសម្រេចគោលដៅនៃការអប់រំៗ*[1]*ការបណ្តុះបណ្តាលដោយវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ* (Holistic Approach) *ក៏ដូចជាវិធីសាស្ត្រពីររួមគ្នា*(Twin

---

[1] *ដកស្រង់ពីគេហទំព័រភ្នំពេញប៉ុស្តិ៍ចុះផ្សាយនៅថ្ងៃទី១ កញ្ញា ២០២១*

Track Approach) បានជួយយ៉ាងច្រើនដល់កុមារក្នុងការអប់រំបរិយាបន្ន។ ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពត្រង់ចំណុចទី៤ «ការអប់រំបរិយាបន្ន សមធម៌ គុណភាព និងការលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា» ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំយកចិត្តទុកដាក់លើកកម្ពស់គុណភាពអប់រំ ជាពិសេសបង្កើនអត្រាឡើងថ្នាក់ កាត់បន្ថយអត្រាបោះបង់ការសិក្សា ផ្តោតសំខាន់លើការអនុវត្តសិទ្ធិកុមារជាមូលដ្ឋានដែលធានាសមធម៌នៃការចូលរៀនរបស់កុមារគ្រប់ប្រភេទ[2]។ ប្រព័ន្ធបរិយាបន្នផ្តល់នូវការអប់រំប្រកបដោយគុណភាពប្រសើរជាងមុន សម្រាប់កុមារទាំងអស់និងជាឧបករណ៍សំខាន់ក្នុងការផ្លាស់ប្តូរឥរិយាបថរើសអើងផងដែរ។ សាលារៀន ផ្តល់នូវបរិបទសម្រាប់ទំនាក់ទំនងដំបូងរបស់កុមារ ជាមួយនឹងពិភពលោកខាងក្រៅគ្រួសាររបស់ពួកគេ ដោយអនុញ្ញាតឱ្យមានការអភិវឌ្ឍទំនាក់ទំនងសង្គម និង អន្តរកម្ម។ ការគោរពនិងការយល់ដឹងកើនឡើងនៅពេលដែលសិស្សមានសមត្ថភាព និងប្រវត្តិផ្សេងៗគ្នា លេងទំនាក់ទំនងសង្គម និងរៀនជាមួយគ្នា។ ទន្ទឹមនឹងនេះ ថ្នាក់អប់រំបរិយាបន្ន គឺដាក់បញ្ចូលកុមារទាំងអស់ឱ្យរៀនជាមួយគ្នានៅក្នុងប្រព័ន្ធអប់រំទាំងក្នុង ឬក្រៅប្រព័ន្ធអប់រំដោយមិនបែងចែកអំពីភេទ អត្តចរិត កាយសម្បទា បញ្ញាស្មារតី ស្ថានភាពសង្គម ភាសាវប្បធម៌ សាសនា ឬលក្ខណៈផ្សេងៗទៀត។ មិនតែប៉ុណ្ណោះ ជនពិការភាពក៏ជាកង្វល់ដ៏ធំធេងមួយដែលយើងមិនអាចមើលរំលងបានទេ។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដើម្បីធានាថាជនមានពិការភាពក៏ដូចជាមនុស្សជាតិទាំងអស់ត្រូវទទួលបានសិទ្ធិដូចគ្នា រួមមានសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ចសង្គម និងសិទ្ធិវប្បធម៌ ដោយគ្មានការបែងចែកនិងរើសអើង។[3]ប្រទេសកម្ពុជា បានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍ដែលបានបន្សល់ទុកនូវផលវិបាកជាច្រើនរួមទាំងជនមានពិការភាពផងដែរ។

ពីឆ្នាំ២០០៨-២០១៨ ក្រសួងបានអនុវត្តគោលនយោបាយស្តីពីការអប់រំកុមារ

[2] ដកស្រង់ពីឯកសារស្តីពីការអប់រំបរិយាបន្ន សម្រាប់គរុសិស្ស ឆ្នាំ២០១៧

[3] ក្រសួងអប់រំ យុវជន និងកីឡា គោលនយោបាយស្តីពីការអប់រំបរិយាបន្ន ទំព័រ១ ឆ្នាំ២០១៨

ពិការដែលធានាចំពោះកុមារ និងយុវជនកម្ពុជាទាំងអស់ឱ្យមានឱកាសស្មើៗគ្នាក្នុងការទទួលបានការអប់រំកម្រិតមូលដ្ឋាន និងក្រៅប្រព័ន្ធ ដោយមិនប្រកាន់កម្រិតជីវភាព ភេទ ភូមិសាស្ត្រ កាយសម្បទា និងជនជាតិឡើយ។

ក្នុងន័យនេះ ការអប់រំបរិយាបន្ន ជាការអប់រំរួមបញ្ចូលដែលធានាគុណភាពសិក្សាធិការដល់មនុស្សគ្រប់រូបគ្រប់ពណ៌សម្បុរ មិនថាមានឬក្រ ស្ថានភាពរស់នៅបែបណានោះទេ។ការអភិវឌ្ឍកាយសម្បទានិងបញ្ញាស្មារតីដល់ជនគ្រប់រូប ជាគន្លឹះចាំបាច់បំផុតក្នុងការអប់រំសម្រាប់ទាំងអស់គ្នា។

## ២.ប្រវត្តិខ្លះៗនៃការអប់រំ

### ២.១.ប្រវត្តិអប់រំ៖

កាលដើមឡើយ រាប់រយពាន់ឆ្នាំ កុមារបានអប់រំខ្លួនឯងតាមរយៈការលេង និងការរុករកដោយខ្លួនឯង។[4] នៅក្នុងសង្គមមុនបេះអក្សរ នេះត្រូវបានសម្រេចដោយផ្ទាល់មាត់ និងតាមរយៈការធ្វើត្រាប់តាម។ ការនិទានរឿងបានឆ្លងកាត់ចំណេះដឹង គុណតម្លៃ និងជំនាញពីមួយជំនាន់ទៅមួយជំនាន់ទៀត។

នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិជាច្រើនសតវត្សន៍ដែលឈានទៅដល់សង្គមកសិកម្មជាង១០ ០០០ឆ្នាំមុន កុមារបានរៀនជំនាញដែលពួកគេត្រូវការសម្រាប់ភាពជោគជ័យក្នុងជីវិតមនុស្សពេញវ័យតាមរបៀបដែលខុសពីអ្វីដែលពួកគេចង់បាននៅពេលក្រោយ។

ការអប់រំមានន័យថា ការសិក្សាដើម្បីទទួលបានចំណេះដឹងនិងការយល់ដឹងកាន់តែស៊ីជម្រៅលើមុខវិជ្ជាផ្សេងៗដែលត្រូវយកមកអនុវត្តក្នុងជីវិតប្រចាំថ្ងៃ។ ការអប់រំ គឺកិច្ចដំណើរការអភិវឌ្ឍការសិក្សាឬការបណ្ដុះបណ្ដាលកាយសម្បទា សតិបញ្ញានិងសីលធម៌តាមរយៈគ្រប់សកម្មភាពអប់រំ។ ការធ្វើឲ្យអ្នកសិក្សាទទួលបាននូវសំណុំចំណេះដឹង ជំនាញសមត្ថភាពនិងតម្លៃ។ ជាការពិតណាស់ ការអប់រំគឺជាសកម្មភាពដែលមានគោលបំណងសំដៅដល់ការសម្រេចបាននូវគោលបំណងមួយចំនួន ដូចជាការបញ្ជូនចំណេះដឹង ឬការជំរុញជំនាញ និងចរិតលក្ខណៈ។ ជាក់ស្តែងដូចជាប្រទេសចិន ការអប់រំបែបប្រពៃណី ត្រូវបានគ្របដណ្តប់ដោយឃូជិ (keju:ប្រព័ន្ធប្រឡងសេវាស៊ីវិល)[5] ដែលបានចាប់ផ្តើម

[4] https://www.psychologytoday.com

[5] civil service examination system

អភិវឌ្ឍប្រហែល ឆ្នាំ400នៃគ្រឹស្តសករាជនិង កាន់តែរីកចម្រើននៅក្នុងរជ្ជកាលរាជវង្សតាំង (ឆ្នាំ៦១៨ដល់៨៩៦នៃគ.ស)។[6]នាអតីតកាល ចិនមានប្រព័ន្ធឃូជិ ហើយសកលលោកក៏ដូច ជាប្រទេសនីមួយៗ ក៏មានកំណែទម្រង់ប្រព័ន្ធ អប់រំដូចគ្នាក្នុងការពង្រឹងគុណភាពអប់រំឱ្យ មានប្រសិទ្ធភាពនិងប្រសិទ្ធផលដោយក្នុង នោះ មានប្រព័ន្ធអប់រំឌីជីថល[7] ប្រព័ន្ធអប់រំ ពិសេស និងប្រព័ន្ធអប់រំបរិយាបន្នជាដើម។

## ២.២.ប្រភេទនៃប្រព័ន្ធអប់រំ

ពាក្យ "ប្រព័ន្ធអប់រំ" រួមមានស្ថាប័នទាំង អស់ដែលពាក់ព័ន្ធនឹងការអប់រំរបស់កុមារ យុវជន និងមនុស្សពេញវ័យ ជាពិសេសមត្តេយ្យ សិក្សា បឋមសិក្សា អនុវិទ្យាល័យ មធ្យមសិក្សា ទុតិយភូមិ ឬកន្លែងហាត់ប្រាណ សាលាវិជ្ជាជីវៈ និងនៅកម្រិតឧត្តមសិក្សាពហុបច្ចេកទេស សាកលវិទ្យាល័យ និងស្ថាប័នអប់រំសម្រាប់ មនុស្សពេញវ័យផងដែរ ដូចជាមជ្ឈមណ្ឌល អប់រំមនុស្សពេញវ័យជាដើម។

រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំមានភាពខុស ប្លែកគ្នារវាងប្រជាជាតិនានា ហើយជួនកាល ផងដែរនៅក្នុងប្រជាជាតិក្នុងតំបន់ឬរដ្ឋផ្សេងៗ គ្នា (ឧទាហរណ៍នៅប្រទេសអាល្លឺម៉ង់)។ ភាព ខុសគ្នាជាក់លាក់ទាក់ទងនឹងសំណួរថាតើនៅ ពេលណាដែលក្មេងឬកុមារត្រូវបានបំបែក និងជ្រើសរើសឱ្យទៅសាលារៀនផ្សេងៗគ្នា។ ការបែងចែកទៅជាប្រភេទសាលាមួយ ឬច្រើន អាចជាការពិតបន្ទាប់ពីបញ្ចប់ការសិក្សារយៈ ពេល 4 ឆ្នាំ ឬក្រោយសាលាបឋមសិក្សា ហើយ នៅក្នុងប្រព័ន្ធមួយចំនួន លទ្ធភាពត្រូវបាន បើកឱ្យលឿនបំផុតដើម្បីបន្តក្នុងផ្លូវផ្សេងៗគ្នា នៅចុងបញ្ចប់នៃប្រភេទនីមួយៗនៃសាលា។[8] នៅក្នុងប្រព័ន្ធមួយចំនួន សាលារៀនមានភាព ទូលំទូលាយជាងយ៉ាងហោចណាស់ក្នុង អំឡុងពេលប្រាំបួនឆ្នាំដំបូង។ ទោះបីជាប្រព័ន្ធ អប់រំផ្សេងៗគ្នាប្រែប្រួលទៅតាមការជ្រើសរើស ឬសិក្សាទូលំទូលាយក៏ដោយ ក៏ប្រព័ន្ធទាំង អស់អាចត្រូវបានចាត់ថ្នាក់តាមស្តង់ដារអន្តរ ជាតិនៃការអប់រំ (ISCED) ដល់កម្រិតជាក់

---

[6] ដកស្រង់និងកែសម្រួលពីអត្ថបទ «ការអប់រំ ជាកិច្ចការទាំងអស់គ្នា» ប៉ាន់ សំណាង ការផ្សាយរបស់ រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០២២

[7] ថ្មីៗនេះ ក្រសួងអប់រំ បានសរសេរសៀវភៅមួយ«ការអប់រំឌីជីថលៈបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ» របស់ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា

[8] https://www.sutori.com

លាក់ក្នុងលក្ខខណ្ឌនៃការអប់រំផ្លូវការ និងក្រៅប្រព័ន្ធ៖ ការអប់រំកុមារតូច (កម្រិត 0), ការអប់រំបឋមសិក្សា (កម្រិតទី 1) មធ្យមសិក្សាទុតិយភូមិ (កម្រិតទី 2) ការអប់រំមធ្យមសិក្សាទុតិយភូមិ (កម្រិតទី 3) ការអប់រំក្រោយមធ្យមសិក្សាមិនមែនឧត្តមសិក្សា (កម្រិតទី 4) ការអប់រំកម្រិតឧត្តមសិក្សារយៈពេលខ្លី (កម្រិតទី 5) បរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ (កម្រិត 6) អនុបណ្ឌិត ឬសមមូល (កម្រិតទី 7) បណ្ឌិត ឬសមមូល (កម្រិតទី 8) និងមិនត្រូវបានចាត់ថ្នាក់នៅកន្លែងផ្សេងទៀត (កម្រិតទី 9) ។ ការស្រាវជ្រាវនេះ យើងធ្វើការស្រាវជ្រាវជាពិសេសលើមនុស្សពេញវ័យដែលមានអាយុពី 18 ទៅ29 ឆ្នាំ ដូច្នេះស្ថាប័ន និងស្ថាប័នអប់រំផ្លូវការ និងក្រៅផ្លូវការដែលទាក់ទងនឹងក្រុមអាយុនេះភាគច្រើនស្ថិតនៅក្នុងកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា ព្រមទាំងកម្រិតអប់រំមនុស្សពេញវ័យផងដែរ។នេះ មានន័យថា កម្រិត ISCED កម្រិត 3, 4, 5 និង 9 មានចំណាប់អារម្មណ៍ជាពិសេសទាក់ទងនឹងការផ្លាស់ប្តូរពីសាលារៀនទៅកន្លែងធ្វើការ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬពីសាលារៀនទៅការអប់រំបន្ថែមរៀងៗខ្លួន ដោយហេតុនេះទាក់ទងនឹងចំណុចនៃការផ្លាស់ប្តូរទាំងនេះជាស្ថានភាពនៃភាពងាយរងគ្រោះផ្នែករចនាសម្ព័ន្ធ។

ដូច្នេះ គំនិតនៃប្រព័ន្ធអប់រំ ជាការរួមបញ្ចូលយ៉ាងពេញលេញ ដែលធ្វើឲ្យសិស្សធ្វងកាត់ត្រូវបានចុះខ្សោយ។ ការបែងចែកប្រភេទនៃប្រព័ន្ធអប់រំដោយយោងទៅតាមការធ្វើមាត្រដ្ឋាន និងស្តង់ដារ។ ទោះជាយ៉ាងណាក៏ដោយ គុណលក្ខណៈទាំងនេះគួរតែត្រូវបានចាត់ទុកថាជាការវាយតម្លៃ។[9]

### ៣.តម្លៃនៃការអប់រំបរិយាបន្ន

ពេលដែលនិយាយពី«ការអប់រំបរិយាបន្ន» ហាក់ដូចជាថ្មី មិនធ្លាប់លឺ តែការអនុវត្តបានដើរមុនបាត់ទៅហើយ ដូចកូនសិស្សខ្លះមានឈ្មោះសុទ្ធតែប្រើភាសាបាលីសំស្ក្រឹត[10] តែខ្លួនមិនស្គាល់និងចេះពាក្យបាលីសំស្ក្រឹតនោះដែរ។ តទៅនេះ សូមអនុញ្ញាតិសិក្សាស្វែងយល់ពីការអប់រំបរិយាបន្នដូចខាងក្រោម៖

[9] https://www.young-adulllt.eu

[10] ឈ្មោះដូចជា«បុប្ផា វិចិត្រ ពជិនី សុខា……»សុទ្ធតែជាពាក្យបាលីសំស្ក្រឹត

### ៣.១.បរិយាបន្ន

*តើបរិយាបន្ន ជាអ្វី?*

*តាម* **និក្ខុហាក់ សៀងហៃ** *ព្រះអង្គមានសង្ឃដីកាបកស្រាយថា ពាក្យ«* ***បរិយាបន្ន*** *» បានមកពី* **«បរិ+ យ+ អា+ បទ+ ត»** មានន័យ *ថារួមបញ្ចូលគ្នា ហើយត្រូវនឹងពាក្យអង់គ្លេស* (Inclusiveness)។ [11] *បើតាមវចនានុក្រម*Oxfort *គឺ បរិយាបន្ន ជាការអនុវត្តឬជាគោលនយោបាយក្នុងការផ្តល់ជូននូវឱកាសនិងធនធានស្មើៗគ្នាសម្រាប់មនុស្សជាតិដែលគេមើលរំលងដោយការទាត់ចោលឬការកាត់បន្ថយដូចជាអ្នកដែលមានពិការភាពផ្លូវកាយឬផ្លូវចិត្តឬផ្តោតលើជនជាតិភាគតិច។* (Inclusiveness: the practice or policy of providing equal access to opportunities and resources for people who might otherwise be excluded or marginalized, such as those having physical or mental disabilities or belonging to other minority groups.)

*ទស្សនៈមួយទៀតបានលើកឡើងថា«បរិយាបន្ន ជាការដាក់បញ្ចូលសមាសភាគផ្សេងៗក្នុងប្រព័ន្ធឬកន្លែងតែមួយ»។*[12]

### ៣.២.ការអប់រំបរិយាបន្ន

*ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពត្រង់ចំណុចទី៤«ការអប់រំបរិយាបន្ន សមធម៌ គុណភាព និងការលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា» ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំយកចិត្តទុកដាក់លើកកម្ពស់គុណភាពអប់រំ ជាពិសេសបង្កើនអត្រាឡើងថ្នាក់ កាត់បន្ថយអត្រាបោះបង់ការសិក្សា ផ្តោតសំខាន់លើការអនុវត្តសិទ្ធិកុមារជាមូលដ្ឋានដែលធានាសមធម៌នៃការចូលរៀនរបស់កុមារគ្រប់ប្រភេទ។* មិនតែប៉ុណ្ណោះ *ក្រសួង ក៏បានរៀបចំគោលនយោបាយស្តីពីការអប់រំបរិយាបន្ន ដែលមានចក្ខុវិស័យ គោលបំណង គោលដៅយុទ្ធសាស្ត្រ ផែនការសកម្មភាព និងការត្រួតពិនិត្យវាយតម្លៃច្បាស់លាស់និងត្រឹមត្រូវ។*

---

[11] *ដកស្រង់ពីផេណេលយូធូប*Hak Sienghai

[12] *ស្រង់ពីគេហទំព័រ*www.sangapac,com



## ក.ការស្វែងយល់ពីការអប់រំបរិយាបន្ន

អង្គការUNESCOឱ្យនិយមន័យការអប់រំបរិយាបន្ន គឺជា «វិធីសាស្ត្រសកម្មនៃការឆ្លើយតបដោយវិជ្ជមានទៅកាន់ភាពចម្រុះគ្នានៃសិស្ស និងការមើលឃើញនូវភាពខុសគ្នារបស់សិស្សមិនមែនជាបញ្ហា ប៉ុន្តែជាឱកាសសម្រាប់ធ្វើឱ្យការសិក្សាប្រសើរឡើង»។

ជាតុផ្សំដែលចាំបាច់នៅក្នុងការកំណត់និយមន័យការអប់រំបរិយាបន្ន៖

- ការអប់រំបរិយាបន្ន ជាការស្វាគមន៍ភាពចម្រុះ
- ជាការផ្តល់អត្ថប្រយោជន៍ដល់សិស្សទាំងអស់មិនមែនផ្តោតលើសិស្សដែលត្រូវផាត់ចេញ
- ការដាក់បញ្ចូលកុមារដែលដែលមានអារម្មណ៍ថាត្រូវបានផាត់ចេញទៅក្នុងសាលារៀន
- ការទទួលបានការអប់រំដោយស្មើភាព
- ការផ្តល់ដោយដាក់លាក់ដល់ក្រុមកុមារដោយមិនផាត់ពួកគេចេញ។

ក្រៅពីនេះ នៅមានជាតុផ្សំសំខាន់៤ទៀតនៅក្នុងការកំណត់បញ្ញត្តិនៃការអប់រំបរិយាបន្ន។ ជាតុទាំង៤មានដូចខាងក្រោម៖

- ការអប់រំបរិយាបន្ន គឺជាដំណើរការស្វែងរកមិនមានទីបញ្ចប់ ដើម្បីរុករកមធ្យោបាយកាន់តែប្រសើរនៃការឆ្លើយតបទៅនឹងភាពចម្រុះ។វាគឺជាការរៀនពីរបៀបរស់នៅជាមួយភាពខុសគ្នានិងរៀនពីភាពខុសគ្នា។ការធ្វើបែបនេះ ភាពខុសគ្នាត្រូវបានមើលឃើញថាកត្តាជំរុញកាន់តែវិជ្ជមានសម្រាប់ជំរុញការរៀននៅក្នុងចំណោមកុមារ និងមនុស្សពេញវ័យ។
- ការអប់រំបរិយាបន្ន គឺជា ការកំណត់អត្តសញ្ញាណនិងលុបបំបាត់ឧបសគ្គ។ ដូច្នោះ វាទាក់ទង

នឹងការប្រមូល រៀបចំ និងវាយតម្លៃព័ត៌មានពីធនធានច្រើនយ៉ាងដើម្បីរៀបចំផែនការសម្រាប់ការធ្វើឱ្យប្រសើរនូវគោលនយោបាយនិងការអនុវត្ត។

- ការអប់រំបរិយាបន្នទាក់ទងវត្តមានការចូលរួម និងការសម្រេចរបស់សិស្សទាំងអស់។ «វត្តមាន»សម្តៅដល់ទីកន្លែងដែលកុមារត្រូវបានអប់រំ និងការមករៀនទៀងទាត់។ «ចូលរួម» ទាក់ទងទៅនឹងគុណភាពបទពិសោធន៍របស់សិស្សដូច្នេះត្រូវរួមបញ្ចូលទស្សនៈរបស់ពួកគេ។ចំណែក«កាសម្រេច» គឺសម្តៅដល់លទ្ធផលនៃការសិក្សានៅក្នុងកម្មវិធីសិក្សាទាំងមូល មិនមែនគ្រាន់តែលទ្ធផលប្រឡងនោះទេ។
- ការអប់រមបរិយាបន្ន ទាក់ទងនឹងការផ្តោតជាពិសេសលើក្រុមសិស្សដែលងាយរងគ្រោះពីការបាត់បង់ឱកាស ការផាត់ចេញ ឬបរាជ័យ។ នេះបញ្ជាក់ពីការទទួលខុសត្រូវសីលធម៌ ដើម្បីធានាថាក្រុមដែលងាយរងគ្រោះបំផុត ត្រូវបានត្រួតពិនិត្យតាមដានដោយយកចិត្តទុកដាក់ និងនៅក្នុងករណីចាំបាច់វិធានការត្រូវបានធ្វើឡើង ដើម្បីធានាវត្តមាន ការចូលរួម និងការសម្រេចរបស់ពួកគេនៅក្នុងប្រព័ន្ធអប់រំ។[13]



**រូបភាពវេទិកាថ្នាក់ជាតិលើកទី៨ស្តីពីការអប់រំបរិយាបន្ន**៖ស្តីពី«បង្កើនការវិនិយោគលើការកសាងសមត្ថភាពគ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀនអំពីការអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព» រៀបចំនៅរាជធានីភ្នំពេញថ្ងៃ១១១២ ខែធ្នូ ឆ្នាំ២០១៩

[13] ក្រសួងអប់រំ យុវជន និងកីឡា ឯកសារស្តីពីការអប់រំបរិយាបន្ន ទំព័រ១០ ឆ្នាំ២០១៧

## ខ.បរិយាកាសសាលារៀនបរិយាបន្ន

រូបខាងក្រោមជាបរិយាកាសសាលារៀនបរិយាបន្ន៖




## គ.វិធីបង្រៀនអប់រំបរិយាបន្ន

### គ.១.ការបង្ហាញវិធីបង្រៀន

វិធីបង្រៀនការអប់រំបរិយាបន្នមិនទទួលយក ឬបដិសេធ៖

- ទស្សនៈដែលគិតថាកុមារមានសមត្ថភាពថេរតែមួយ
- ការរៀនរបស់កុមារពេលបច្ចុប្បន្នអាចយកទៅព្យាករណ៍សក្តានុពលនាពេលអនាគត
- បញ្ញាអាចកំណត់តាមរយៈពេលធ្វើតេស្តផ្អែកលើជំនាញតក្កវិជ្ជា គណិតវិទ្យា ទាញហេតុផល។ ផ្ទុយមកវិញ វិធីបង្រៀនការអប់រំបរិយាបន្នមានជំនឿថា៖
- សមត្ថភាពកុមារគ្រប់គ្នាក្នុងការរៀនមានការផ្លាស់ប្តូរ
- អ្វីដែលគ្រូបង្រៀនជ្រើសរើសធ្វើ ឬមិនធ្វើនាពេលបច្ចុប្បន្នអាចផ្លាស់ប្តូរសមត្ថភាពរៀនរបស់កុមារនាពេលអនាគត។

វិធីបង្រៀនការអប់រំបរិយាបន្នអាចត្រូវរៀបចំ និងអនុវត្តនៅក្នុងរបៀបដែលពាក់ព័ន្ធ មានន័យគ្រប់គ្រាន់និងអាចទទួលយកបានដោយកុមារទាំងអស់។ ដូច្នេះគរុសិស្ស ត្រូវយល់ដឹងពី៖

- ចរិតលក្ខណៈនៃគ្រូបង្រៀនបរិយាបន្ន
- វិធីដែលគ្រូបង្រៀនអាចបំពេញសេចក្តីត្រូវការផ្សេងៗនៅក្នុងថ្នាក់រៀន

- ពហុបញ្ញា
- របៀបរៀន
- ការកំណត់ឧបសគ្គដែលកុមារអាចមាននៅក្នុងការរៀន
- មូលហេតុការរៀនតាមរយៈការលេង និងសិល្បៈច្នៃប្រឌិតអាចលើកកម្ពស់ការរៀន
- ការដាក់បញ្ចូលកុមារទាំងអស់នៅក្នុងការរៀន តាមរយៈការការប្រើប្រាស់បួងសកលសម្រាប់ការរៀន
- របៀបបង្កើតផែនការអប់រំសិស្សម្នាក់ៗមានប្រយោជន៍សម្រាប់គ្រូបង្រៀន ដើម្បីតាមដានសេចក្ដីត្រូវការរបស់កុមារម្នាក់ៗដែលត្រូវការគាំទ្របន្ថែម......។

**គ.២.ការរៀនតាមរយៈការលេងកំសាន្ត**

ការរៀនតាមរយៈការលេង និងបរិស្ថានបានក្លាយជាប្រធានបទថ្មីមួយសម្រាប់អប់រំកុមារកម្ពុជា។

ការលេងមានភាពសប្បាយរីករាយសម្រាប់កុមារ ប៉ុន្តែវាក៏អាចជួយពង្រឹងគោលគំនិតអប់រំ និងសម្រួលដល់ការរៀនសូត្រផងដែរ។ តាមរយៈការលេង និងហ្គេម កុមារមិនគ្រាន់តែនៅក្នុងមេរៀនប៉ុណ្ណោះទេ ថែមទាំងមានភាពសប្បាយរីករាយផងដែរ។ សាលាបញ្ចប់ការសិក្សារបស់ Harvard បានបោះពុម្ពផ្សាយរឿងមួយដែលមានចំណងជើងថា "ការលេងដើម្បីរៀន" ដែលរៀបរាប់លម្អិតអំពីរបៀបដែលការលេងគឺជាផ្នែកសំខាន់មួយនៃការរៀនសូត្រ និងរបៀបដែលប្រទេសដាណឺម៉ាក និងអាហ្វ្រិកខាងត្បូងរួមបញ្ចូលម៉ោងលេងទៅក្នុងម៉ោងសិក្សា។ការអប់រំកុមារតូចជាចំណុចយ៉ាងសំខាន់បំផុតក្នុងចំណោមដំណាក់កាលនានានៃការអប់រំ ព្រោះវ័យនេះជាវ័យដែលត្រូវការយកចិត្តទុកដាក់ ខ្ពស់ និងជាវ័យចាប់ផ្ដើមកំណត់ពីដំណើរជីវិតរបស់កុមារ។

ដោយមើលឃើញពីសារៈសំខាន់នៃការអប់រំកុមារតូច ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់ជំរុញការអប់រំកុមារតូចដោយការបង្កើតកម្មវិធីអប់រំថ្មីៗដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់។ ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសម្ពោធអគារសិក្សានៃសាលាមត្តេយ្យសិក្សាធនធានបាត់ដំបង និង សម្ពោធបើកដំណើរការគម្រោងកសាងមូលដ្ឋានគ្រឹះនៃការអនុវត្ត

ទ្រឹស្តី "រៀនតាមរយៈ ការលេង និង បរិស្ថាន" ដើម្បីជំរុញការអប់រំកុមារតូចឱ្យកាន់តែមានសមត្ថភាពខ្លាំង។

អ្នកស្រាវជ្រាវណែនាំថា ការលេងគឺជាធាតុផ្សំសំខាន់ក្នុងការរៀនសូត្រ អនុញ្ញាតឱ្យកុមារធ្វើត្រាប់តាមអាកប្បកិរិយារបស់មនុស្សពេញវ័យ អនុវត្តជំនាញសំខាន់ៗ ដែលមានដំណើរការប្រកបដោយចិត្តរំភើប និងរៀនច្រើនអំពីពិភពលោករបស់ពួកគេ។[14]



រូបភាពរបស់គេហទំព័រ bizkhmer៖ រៀនដោយស្នាមញញឹមរបស់កុមារមានពិការភាព

## គ.៣.ការអភិវឌ្ឍជំនាញប្រាស្រ័យទាក់ទងល្អ

ឥទ្ធិពលនៃពាក្យសម្តីរបស់អ្នក អាចបង្កើតនូវសម្ពន្ធភាពមួយដ៏ស្អិតរមួត ប្រកបដោយការយល់ចិត្តយល់ថ្លើមគ្នាទៅវិញទៅមក ឬជាសម្ពន្ធភាពមួយដែលមានភាពល្អក់កករនឹងគ្នាកើតឡើងដោយសារការយល់ច្រឡំចំពោះគ្នាបាន។ ចំណុចនេះ បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពសំខាន់នៃការប្រាស្រ័យទាក់ទងទៅលើគុណភាពនៃសម្ពន្ធភាពក្នុងជីវិតអ្នក។ ការយល់ដឹងពីរបៀបនៃការប្រាស្រ័យទាក់ទងបែបណាទើបអាចបណ្តុះបាននូវទំនាក់ទំនងរបស់អ្នក និងមនុស្សជុំវិញខ្លួនឲ្យប្រព្រឹត្តទៅដោយភាពវិជ្ជមាន នឹងបង្កើតបាននូវទំនុកចិត្តរវាងគ្នា ការយល់ចិត្តគ្នា និងឈានទៅដល់ការបំពេញប្រយោជន៍ឲ្យគ្នាទៅវិញទៅមកបានយ៉ាងគាប់ប្រសើរផងដែរ។ ខាងក្រោមនេះ គឺជាចំណុចទាំង៤ដែលនិយាយអំពីជំនាញក្នុងការប្រាស្រ័យទាក់ទងដែលមនុស្សគ្រប់រូបគួររៀនសូត្រ៖

**១. កាយវិការ** ទោះជាពាក្យសម្តីរបស់អ្នកមានឥទ្ធិពលយ៉ាងណាក៏ដោយ ប្រសិនបើកាយវិការរបស់អ្នកមិនបង្ហាញពីជំនឿជាក់និងភាពរួសរាយរាក់ទាក់របស់អ្នកទេនោះ អ្នកនឹងគ្មានឥទ្ធិពលអ្វីទៅលើពួកគេនោះឡើយ។

[14] Researchers suggest that play is a central ingredient in learning, allowing children to imitate adult behaviors, practice motor skills, process emotional events, and learn much about their world.

**២. យកចិត្តទុកដាក់ស្តាប់យ៉ាងសកម្ម** ការប្រាស្រ័យទាក់ទងមួយដែលល្អ មិនមែនគ្រាន់តែជាការប្រើប្រាស់ពាក្យសម្តី និងកាយវិការឲ្យបានសមរម្យនោះទេ អ្នកត្រូវបណ្តុះទម្លាប់ក្នុងការស្តាប់ដែគួរបស់អ្នកដោយការយកចិត្តទុកដាក់ និងស្តាប់ចេញពីចិត្ត ព្រមទាំងយល់បានច្បាស់ពីខ្លឹមសារដែលពួកគេកំពុងនិយាយផងដែរ។

**៣. ការដោះស្រាយភាពមិនចុះសម្រុងគ្នា** ថ្វីបើមនុស្សភាគច្រើនជ្រើសរើសចៀសវាងពីភាពទាស់ទែងគ្នា ក៏ព្រោះតែពួកគេរៀងខ្លួនមិនចង់ទទួលនូវអារម្មណ៍ល្អក់កករ និងការឈឺចាប់តែការដោះស្រាយភាពមិនចុះសម្រុងគ្នាទាំងឡាយជាមួយដៃគូសន្ទនារបស់អ្នក គឺជារឿងមួយដ៏សំខាន់បំផុតក្នុងការរក្សាបាន និងពង្រឹងនូវសម្ពន្ធភាពរបស់អ្នកជាមួយពួកគេ។ កាលណាអ្នកបានគ្រប់គ្រងទៅលើអារម្មណ៍របស់អ្នកបាន ដោយឆ្លើយតបទៅកាន់ពួកគេវិញជាមួយការតាំងចិត្តឲ្យស្ងប់ មិនព្យាយាមនិយាយការពារខ្លួនឯង និងមានការគោរពចំពោះគ្នា នោះគំនិតរបស់អ្នកក៏នឹងទទួលបានការស្តាប់ពីអ្នកដទៃ រហូតឈានដល់ការសម្របសម្រួលគ្នាមួយយ៉ាងពេញចិត្តពេញថ្លើម។

**៤. ចោទសួរនូវសំណួរដ៏ល្អ** សំណួរដែលមានលក្ខណៈបើកចំហ ដែលបំផុសពីអារម្មណ៍ដែលកប់ជ្រៅនៅក្នុងជម្រៅចិត្តរបស់ពួកគេទៅលើហេតុការណ៍សំខាន់ណាមួយ គឺជាសំណួរដែលបង្ហាញពីការយកចិត្តទុកដាក់របស់អ្នកទៅលើពួកគេ និងចំណាប់អារម្មណ៍របស់អ្នកចំពោះការប្រាស្រ័យទាក់ទងនោះដែលវានឹងលើកទឹកចិត្តពួកគេឲ្យបើកចំហក្នុងការចែករំលែកពីខ្លួនពួកគេកាន់តែច្រើនជាងមុន។ ម្យ៉ាងទៀត អ្នកមិនត្រូវចូលទៅនិយាយកាត់ពួកគេ នៅពេលភាពស្ងប់ស្ងាត់បានលេចមកនោះទេ ព្រោះថាអាចជាភាពស្ងប់ស្ងាត់មួយរំពេចនេះហើយ ដែលជាឱកាសឲ្យពួកគេនិយាយពីរឿងក្នុងចិត្តប្រាប់អ្នកច្រើនជាងមុននោះ។[15]

ជាការពិតណាស់ ការលើកឡើងមកខាងលើ សុទ្ធជាមធ្យោបាយគន្លឹះល្អៗ ហើយវាក៏អាចជួយដល់កុមារឬសិស្សានុសិស្សកសាងជំនាញប្រាស្រ័យទាក់ទងបានល្អដែរ។ដើម្បីឱ្យក្មេងទទួលបានលទ្ធផល គ្រូបង្រៀនត្រូវយល់

[15] ដកស្រង់ពីគេហទំព័រwww.bizkhmer.com

ដឹងពីជំនាញចាំបាច់ដូចរៀបរាប់មកនិងចេះកំណត់ពីការពិបាកនៃការប្រាស្រ័យទាក់ទង ចេះបំពេញតម្រូវការគាំទ្រការប្រាស្រ័យទាក់ទងជាដើម។

ពីរ៉ាមីតប្រាស្រ័យទាក់ទង ៦០




## គ.៤.ការប្រើប្រាស់វិធីបង្រៀននិងរៀនសកម្ម

ការបង្រៀន យើងត្រូវចេះកំណត់សកម្មភាពទាំងវិធីបង្រៀននិងរៀនសកម្ម និងអកម្ម ហើយប្រើប្រាស់វិធីរៀនបែបសហការប្រកបដោយប្រសិទ្ធភាព។ការរៀនបែបសហការ គឺផ្អែកលើទស្សនៈថា ចំណេះដឹងជាការបង្កើតសង្គម។សកម្មភាពសហការជាទូទៅមានមូលដ្ឋានលើគោលការណ៍៤៖

1. អ្នករៀនគឺជាចំណុចផ្ដោតសំខាន់នៃការបង្រៀន
2. ទំនាក់ទំនង និងការធ្វើសកម្មភាព គឺជាចំណុចសំខាន់បំផុត
3. ការធ្វើការងារជាក្រុម គឺជារបៀបរៀនសំខាន់
4. វិធីសាស្ត្រជាប្រព័ន្ធ ដើម្បីបង្កើតដំណោះស្រាយចំពោះបញ្ហាជាក់ស្ដែងគួរដាក់បញ្ចូលក្នុងការរៀន។



### ៣.៣.តម្លៃនៃការអប់រំបរិយាបន្ន

ការអប់រំបរិយាបន្ន គឺជាតម្លៃនៃភាពចម្រុះ និងការរួមចំណែកតែមួយគត់ដែលសិស្សម្នាក់ៗនាំយកមកក្នុងថ្នាក់រៀន។ នៅក្នុងការកំណត់ដែលរួមបញ្ចូលយ៉ាងពិតប្រាកដ កុមារគ្រប់រូបមានអារម្មណ៍ថាមានសុវត្ថិភាព និងមានភាពជាម្ចាស់។ សិស្ស និងឪពុកម្តាយរបស់ពួកគេចូលរួមក្នុងការកំណត់គោលដៅសិក្សា និងចូលរួមក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់ពួកគេ។ ហើយបុគ្គលិកសាលាមានការបណ្តុះបណ្តាល ការគាំទ្រ ភាពបត់បែន និងធនធាន ដើម្បីចិញ្ចឹមបីបាច់ លើកទឹកចិត្ត និងឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សទាំងអស់។

ប្រព័ន្ធអប់រំបរិយាបន្ន ផ្តល់នូវការអប់រំប្រកបដោយគុណភាពកាន់តែប្រសើរសម្រាប់កុមារទាំងអស់ និងជាឧបករណ៍សំខាន់ក្នុងការផ្លាស់ប្តូរអាកប្បកិរិយារើសអើង។ សាលារៀនផ្តល់បរិបទសម្រាប់ទំនាក់ទំនងដំបូងរបស់កុមារជាមួយពិភពលោកនៅខាងក្រៅគ្រួសាររបស់ពួកគេ ដោយអនុញ្ញាតឱ្យមានការអភិវឌ្ឍទំនាក់ទំនងសង្គម និងអន្តរកម្ម។ ការគោរព និងការយល់ដឹងកើនឡើងនៅពេលដែលសិស្សដែលមានសមត្ថភាព និងប្រវត្តិផ្សេងៗគ្នា លេង ធ្វើសង្គម និងរៀនជាមួយគ្នា។ ការអប់រំដែលមិនរាប់បញ្ចូលនិងបែងចែកដាច់ដោយឡែកបន្តការរើសអើង ប្រឆាំងនឹងក្រុមដែល មានលក្ខណៈតិចតួចតាមប្រពៃណី។ នៅពេលដែលការអប់រំមានលក្ខណៈរួមបញ្ចូលកាន់តែច្រើន គំនិតនៃការចូលរួមរបស់ប្រជាពលរដ្ឋ ការងារ និងជីវិតសហគមន៍។



### ៤.ការសន្និដ្ឋាន

ការអប់រំបរិយាបន្ន គឺជាការឆ្លើយតបទៅនឹងបរិបទថ្មីរបស់ពិភពលោក ក៏ដូចជាតំបន់ដែលមានការអភិវឌ្ឍរីកចម្រើនឥតឈប់ឈរ។ គ្រប់ស្ថាប័នពាក់ព័ន្ធក៏ដូចក្រសួងអប់រំ បានដាក់ចេញនូវផែនការអប់រំ យុទ្ធសាស្រ្ត ស្របតាមគោលនយោបាយការអប់រំបរិយាបន្ន ដោយលៃយ៉ាងណាឱ្យប្រព័ន្ធអប់រំបរិយាបន្ន

ផ្តល់នូវការអប់រំប្រកបដោយគុណភាពកាន់តែប្រសើរសម្រាប់កុមារ និងយុវជនទាំងអស់ ។

ប្រទេសកម្ពុជាស្ថិតនៅលើផ្លូវបង្កើតការអប់រំបរិយាបន្នសម្រាប់កុមារពិការ ចាប់តាំងពីឆ្នាំ២០០៣ ជាមួយការបង្កើតកម្មវិធីសិក្សាអប់រំបរិយាបន្នសម្រាប់កុមារមានសេចក្តីត្រូវការអប់រំពិសេស។ ក្រោយមកទៀត សៀវភៅការអប់រំបញ្ចូលគ្នា ត្រូវបានបង្កើតនៅក្នុងឆ្នាំ២០១២។ បន្ទាប់មកសៀវភៅការបញ្ចូលគ្នាសម្រាប់ កុមារមានបញ្ហាបញ្ញាកុមារមានបណ្តាស្តាប់ និងកុមារមានបញ្ហាការមើលត្រូវបានបង្កើតឡើង។ ឯកសារទាំង នេះផ្តោតសំខាន់លើការសិក្សាប្រភេទពិការ និងផ្តល់គន្លឹះបង្រៀនមួយចំនួនសម្រាប់ប្រភេទពិការផ្សេងៗនៅក្នុងថ្នាក់រៀនបរិយាបន្ន។ ការអភិវឌ្ឍកាយសម្បទានិងបញ្ញាស្មារតីដល់ជនគ្រប់រូប ជាគន្លឹះចាំបាច់បំផុតក្នុងការអប់រំសម្រាប់ទាំងអស់គ្នា។

«***កុមារដែលគ្មានការអប់រំ ប្រៀបដូចជាបក្សីគ្មានស្លាប***»

**ឯកសារពិគ្រោះ**


-ក្រសួងអប់រំ ***គោលនយោបាយស្តីពីការអប់រំបរិយាបន្ន*** ២០១៨

-ក្រសួងអប់រំ ***ឯកសារការអប់រំបរិយាបន្ន ២០១៧***

-ជួន ណាត ***វចនានុក្រមខ្មែរ*** ការផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ១៩៦៧

-ប៉ាន់ សំណាង ***ការអប់រំ ជាកិច្ចការទាំងអស់គ្នា*** ផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ២០២២


**ប្រភពគេហទំព័រ**


-https://www.aii.edu.kh

-https://www.bizkhmer.com

-https://dict.antkh.com

-https://m.postkhmer.com

-https://www.opensocietyfoundations.com

- https://www.psychologytoday.com

-https://www.unicef.org

-https://www.sangapac.com

-https://education.stateuniversity.com

-https://verywellmind.com

- https://www.sutori.com

- https://www.young-adullt.eu

-Channel YouTube: Hak Sienghai